ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៣៥៥៩ កសក

# លិខិតឆ្លងដែន

ហេហ

គោរពជូន៖ -ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | -របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំឆមាសទី១ ឆ្នាំ២០២២** និងទិសដៅអនុវត្តបន្ត ............ | ១ច្បាប់ | "ដើម្បីជូនជ្រាប" --------- |

ថ្ងៃ សុក្រ ១០កើត ខែ អាសាឍ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០២២

ត.ប.រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គលេខាធិការ

ស្រី វុឌ្ឍី

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆមាសទី១ ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆមាសទី១នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ១ ៤៨៣ ១៧២ហ.ត ស្មើនឹង៥៦,៦២% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆមាសទី១ ឆ្នាំ២០២២នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពិចម្លាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២២ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០២២ នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ១ ៦៣៩ ៤៨៩ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ២ ៤៩៤ហ.ត ស្មើនឹង០,១៥% និងដោយគ្រឿងយន្តចំនួន ១ ៦៣៦ ៩៩៥ហ.ត ស្មើនឹង៩៩,៨៥% តិចជាងឆ្នាំមុន ៥០៥ ៥១៧ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៥ ៩៦៦ហ.ត តិចជាងឆ្នាំមុន ៣ ៩៧៣ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ១ ៤៨៣ ១៧២ហ.ត ស្មើនឹង៥៦,៦២% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត តិចជាងឆ្នាំមុន ៤៩៩ ៨៧៣ហ.ត។

#### ១.២ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៣១ ៣៧១ហ.ត ស្មើនឹង៥៤,១៨% នៃផែនការចំនួន ៥៧ ៩០០ហ.ត តិចជាងឆ្នាំមុន ១១ ៨៣១ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៦២៤ ៤៩៩ហ.ត ស្មើនឹង៨០,២៤% នៃផែនការចំនួន ៧៧៨ ៣០០ហ.ត តិចជាងឆ្នាំមុន ២៥ ១៩៧ហ.ត។

#### ១.៣ ការនាំចេញផលិតផលកសិកម្ម

##### ១.៣.១ ការនាំចេញអង្ករ

បរិមាណការនាំចេញអង្ករក្នុងឆមាសទី១ ឆ្នាំ២០២២ មានចំនួន ៣២៧ ២០០តោន កើនឡើងចំនួន ៤៦ ៧៥០តោន (១៦,៦៧%) បើធៀបនឹងបរិមាណនាំចេញក្នុងឆមាសទី១ឆ្នាំ២០២១ ដែលមានចំនួន ២៨០ ៤៥០តោន។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

បរិមាណអង្ករការនាំចេញអង្ករក្នុងខែមិថុនា ឆ្នាំ២០២២ មានចំនួន ៤៣ ៥២៥តោន ថយចុះចំនួន ៣ ៨៩៤តោន (-៨,២១%) បើធៀបនឹងខែមិថុនា ឆ្នាំ២០២១ ដែលមានចំនួន ៤៧ ៤១៩តោន។

អង្ករក្រអូបគ្រប់ប្រភេទចំនួន ២០៧ ២៧១តោន ស្មើនឹង ៦៣,៣៥% អង្ករសគ្រប់ប្រភេទចំនួន ១១៣ ៦១៧តោន ស្មើនឹង ៣៤,៧២% និងអង្ករចំហុយគ្រប់ប្រភេទមានចំនួន ៦ ៣១២តោន ស្មើនឹង ១,៩៣%។

បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២៣ប្រទេស មានបរិមាណសរុបចំនួន ៩៨ ៦២៤តោន (កើនឡើងចំនួន ៣១ ៤៨៨តោន ស្មើនឹង ៤៦,៩០%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១៦៨ ២៨០តោន (កើនឡើងចំនួន ២៤ ៩៨៧តោន ស្មើនឹង ១៧,៤៤%) ទិសដៅអាស៊ានចំនួន ៤ប្រទេស មានបរិមាណសរុបចំនួន ២៨ ៦៨០តោន(កើនឡើងចំនួន ១ ៥៤៤តោន ស្មើនឹង ៥,៦៩%) និងទិសដៅដទៃទៀតចំនួន២៣ប្រទេស មានបរិមាណសរុប ៣១ ៦១៦តោន (ថយចុះចំនួន ១១ ២៦៩តោន ស្មើនឹង -២៦,២៨%)។

ក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៥៣ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ២២៤ ០៩៣តោន (៦៨,៤៩%) និងក្រុមហ៊ុន ៤៣ដទៃទៀតបាននាំចេញត្រឹមតែ ១០៣ ១០៧តោន (៣១,៥១%)។

**១.៣.២ ការនាំចេញស្រូវ**

ក្នុងឆមាសទី១ ឆ្នាំ២០២២ ការនាំចេញស្រូវមានចំនួន ១ ៧៣៣ ១៥៧តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ១៤២ ១៧៥តោន) មានការកើនឡើងចំនួន ៤០ ៣៤៤តោន (២,៣៨%) បើធៀបនឹងឆមាសទី១ ឆ្នាំ២០២១ ដែលមានចំនួន ១ ៦៩២ ៨១៣តោន។

**១.៣.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ**

ក្នុងឆមាសទី១ ឆ្នាំ២០២២ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ៣ ៥៦៦ ០៥០,២៥តោន កើនឡើងចំនួន ២៩៥ ៦០១,៩២តោន ស្មើនឹង ៩,០៤% បើធៀបនឹងឆមាសទី១ ឆ្នាំ២០២១ មានចំនួន ៣ ២៧០ ៤៤៨,៣៣តោន ដែលក្នុងនោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ១ ៥៣៤ ៥៩០តោន (កើនឡើងចំនួន ២៤,២៥%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ១ ១៣៣ ៥៥០តោន និងប្រទេសវៀតណាមចំនួន ៤០១ ០៤០តោន
- ដំឡូងមីស្រស់មានចំនួន ៧១០ ៣០០តោន (កើនឡើងចំនួន ៩៧,៩៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៤៧៥ ១០០តោន និងប្រទេសថៃចំនួន ២៣៥ ២០០តោន
- ម្សៅដំឡូងមីមានចំនួន ៤៨ ៩៤៨តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៤៧ ៤០៥តោន សហរដ្ឋអាមេរិកចំនួន ៦៦តោន ប្រទេសអ៊ីតាលីចំនួន ៣៧៨តោន ប្រទេសវៀតណាមចំនួន ២១០តោន ប្រទេសណេដឺឡែនចំនួន ១៥២តោន ប្រទេសថៃចំនួន ៩៨,៦០តោន និងប្រទេសម៉ាឡេស៊ីចំនួន ៣៨,៤០តោន
- កាកសំណល់ដំឡូងមីមានចំនួន ៧ ០៨១,៣៩តោន (កើនឡើងចំនួន ៦៣,៨១%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៦ ៥៨១,៣៩តោន និងប្រទេសវៀតណាមចំនួន ៥០០តោន
- គ្រាប់ស្វាយចន្ទីឆៅមានចំនួន ៤១៥ ៥៩០,១៥តោន (ថយចុះចំនួន -៥០,៦០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៤១៣ ៣៦៦,២២តោន ប្រទេសថៃចំនួន ២ ០៥០តោន ប្រទេសឥណ្ឌាចំនួន ១៥០,១៦តោន ប្រទេសចិនចំនួន ១៣,៥៨តោន ប្រទេសជប៉ុនចំនួន ០,១៤តោន និងប្រទេសហ្វីលីពីនចំនួន ០,០៥តោន
- គ្រាប់ស្វាយចន្ទីកែច្នៃមានចំនួន ៣០១,៤៣តោន (ថយចុះចំនួន -៦៨,៣៩%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១៣៦,៦៨តោន ប្រទេសថៃចំនួន ១៣៤តោន ប្រទេសជប៉ុនចំនួន ២០,៩៥តោន និងកោះតៃវ៉ាន់ចំនួន ៩,៨០តោន
- គ្រាប់ពោតមានចំនួន ៨៤ ៨៩៨,៩០តោន (ថយចុះចំនួន -៣៩,៦៥%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៧៦ ៥៤០តោន ប្រទេសថៃចំនួន ៧ ៥០០តោន កោះតៃវ៉ាន់ចំនួន ៨៤៦,៦០តោន និងប្រទេសកូរ៉េចំនួន ១២,៣០តោន
- គ្រាប់សណ្តែកបាយមានចំនួន ២៤ ៨០០,០១តោន (កើនឡើងចំនួន ៣៣,៤៨%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ២៤ ៨០០តោន និងប្រទេសជប៉ុនចំនួន ០,០១តោន
- គ្រាប់សណ្តែកសៀងមានចំនួន ៦៧ ០១០តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦៣ ១១០តោន និងប្រទេសថៃចំនួន ៣ ៩០០តោន
- ផ្លែចេកស្រស់មានចំនួន ២១៨ ៩៩០,៦៦តោន (ថយចុះចំនួន -៧,៦៤%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១៩៨ ១៥៤,០៦តោន និងប្រទេសវៀតណាមចំនួន ២០ ៨៣៦,៦០តោន

- ផ្លែស្វាយស្រស់មានចំនួន ១១៥ ៩៥១,៥៥តោន (ថយចុះចំនួន -២៧,៤៣%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦១ ៣៩០,២៣តោន ប្រទេសចិនចំនួន ២៧ ៤៦៧,៨៨តោន ប្រទេសថៃចំនួន ២៦ ៩៣១,១២តោន ប្រទេសកូរ៉េចំនួន ១៦០,០៨តោន និងទីក្រុងហុងកុងចំនួន ២,២៤តោន

- ដំណាប់ស្វាយមានចំនួន ១១ ៧៦៨,៦៤តោន (ថយចុះចំនួន -៧,៨៣%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១០ ៤៧២,៩២តោន ប្រទេសថៃចំនួន ៦៣៣,១៥តោន ប្រទេសហ្វីលីពីនចំនួន ៣៩៦,៨៧តោន ប្រទេសវៀតណាមចំនួន ២០០តោន ប្រទេសជប៉ុនចំនួន ៤៨,៣៨តោន ចក្រភពអង់គ្លេសចំនួន ៩,៧៨តោន ប្រទេសកូរ៉េចំនួន ៤,៩៩តោន ប្រទេសអ៊ីតាលីចំនួន ២,៥២តោន និងសហរដ្ឋអាមេរិកចំនួន ០,០៣តោន

- ដូងប្រេងមានចំនួន ២៤ ៥៧៨,៧០តោន (កើនឡើងចំនួន ០,៦៦%) ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ២០ ០៨៦,៧០តោន ប្រទេសម៉ាឡេស៊ីចំនួន ៤ ៣០០តោន និងប្រទេសថៃចំនួន ១៩២តោន

- ម្រេចមានចំនួន ៦ ២៧២,៩៥តោន (ថយចុះចំនួន -៥៦,៩២%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥ ៦៩២,៥១តោន ប្រទេសអាល្លឺម៉ង់ចំនួន ៥០៥,៧៨តោន កោះតៃវ៉ាន់ចំនួន ២១តោន ប្រទេសម៉ាឡេស៊ីចំនួន ១៣,៦៤តោន ប្រទេសបារាំងចំនួន ១២,២១តោន ប្រទេសប៊ែលហ្សិកចំនួន ៨,៨០តោន សាធារណរដ្ឋឆែកចំនួន ៧,៨៨តោន ប្រទេសស៊ុយអ៊ែតចំនួន ២,៧៨តោន ប្រទេសជប៉ុនចំនួន ២,៤៧តោន ប្រទេសកាណាដាចំនួន ១,២៨តោន សហរដ្ឋអាមេរិកចំនួន ០,៩២តោន ប្រទេសឥណ្ឌាចំនួន ០,៩២តោន ចក្រភពអង់គ្លេសចំនួន ០,៩០តោន ប្រទេសកូរ៉េចំនួន ០,៦២តោន ប្រទេសលីទុយអានីចំនួន ០,៤៥តោន ប្រទេសស្វីសចំនួន ០,៤០តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,២៩តោន និងប្រទេសអូស្ត្រាលីចំនួន ០,១០តោន

- ថ្នាំជក់មានចំនួន ២ ៣៧៣,៩៣តោន (កើនឡើងចំនួន ៣៩,៦៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ២ ២៨៧,៧០តោន ប្រទេសហុងគ្រីចំនួន ៣៩,៦០តោន កោះតៃវ៉ាន់ចំនួន ៣១,៥០តោន ប្រទេសហ្វីលីពីនចំនួន ១៥,១១តោន និងប្រទេសអាហ្វ្រិកខាងត្បូងចំនួន ០,០២តោន

- បន្លែចម្រុះមានចំនួន ៤៨,៤០តោន (កើនឡើងចំនួន ៧,៧៥%) ក្នុងនោះនាំចេញទៅប្រទេសបារាំងចំនួន ៤៨,៣៦តោន និងប្រទេសនូវែលសេឡង់ចំនួន ០,០៤តោន

- ផលិតផលចំនួន ៦៩មុខ ផ្សេងទៀតមានចំនួន ២៩២ ៥៥៥,៥៤តោន។

**១.៣.៤ ការប៉ាន់ស្មានតម្លៃនៃការនាំចេញកសិផល**

ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់ក្នុងឆមាសទី១ឆ្នាំ២០២២ ដែលទទួលបានពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) មានចំនួន ២ ១៩៧ ១៦៨ ៧៦៨,៤៧ដុល្លារអាមេរិក ដែលក្នុងនោះ៖

- ការនាំចេញអង្ករមានចំនួន ២៧៩ ៧៥៦ ០០០ដុល្លារអាមេរិក
- ការនាំចេញស្រូវមានចំនួន ៣៣៦ ២៣២ ៤៥៨ដុល្លារអាមេរិក
- ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ១ ៥៨១ ១៨០ ៣១០,៤៧ដុល្លារអាមេរិក។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ០៤៤ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ៩៤៤ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៣ ៦៩៨ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១០ ១៩៣ហ.ត ស្មើនឹង៧៧% និងផ្ទៃដីថែទាំចំនួន ៩៣ ៨៥១ហ.ត ស្មើនឹង២៣%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូរយៈពេល៥ខែសម្រេចបានចំនួន ១០៤ ៥៧៥តោន កើនឡើងចំនួន ១ ៨០៩តោន ស្មើនឹង២% ធៀបរយៈពេល៥ខែ ឆ្នាំ២០២១
- ផលិតផលឈើកៅស៊ូរយៈពេល៥ខែសម្រេចបានចំនួន ១៣ ០២៦ម៣។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូរយៈពេល៥ខែសម្រេចបានចំនួន ១០៥ ០៤៨តោន កើនឡើងចំនួន ២ ៦៧៤តោន ស្មើនឹង៣% ធៀបរយៈពេល៥ខែ ឆ្នាំ២០២១

- បរិមាណបញ្ចេញលក់ឈើកៅស៊ូរយៈពេល៥ខែសម្រេចបានចំនួន ១២ ០៨១ម៣។

**២.៤ តម្លៃកៅស៊ូ**

- តម្លៃលក់ជ័រកៅស៊ូមធ្យមរយៈពេល៥ខែ គឺ១ ៦០៤ដុល្លារ/តោន ថយចុះចំនួន ៧១ដុល្លារ/តោន ស្មើនឹង៤% ធៀបរយៈពេល៥ខែ ឆ្នាំ២០២១

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារខែឧសភា គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ៨០០៛/គ.ក្រ ដល់ ៦ ២០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៥៥០៛/គ.ក្រ ដល់ ៣ ២៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ទាញយករូបភាពផ្កាយរណប (SENTINEL_2) ឆ្នាំ២០២២ ចំនួន ១៩ផ្ទាំង និងបានចាត់បឋមសម្រាប់ចុះពិនិត្យជាក់ស្តែងនៅទីវាល

- ចុះធ្វើការប្រមូលព័ត៌មាននៅទីវាលជាក់ស្តែងតាមចំណុចនិយាមកាមួយចំនួនដែលបានធ្វើការចាត់ថ្នាក់បឋមតាមរូបភាពផ្កាយរណប SENTINEL-2 ក្នុងកម្មវិធី eCognition មានភាពមិនច្បាស់លាស់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងវាយតម្លៃកម្រិតជឿជាក់នៅខេត្តក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងខេត្តព្រះវិហារ សរុបចំនួន ១ ១៣៥ចំណុច

- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ៤កន្លែង មានផ្ទៃដីព្រៃសរុបទំហំ ៥ ៥៤៧,៤៦ហ.ត (ព្រៃសហគមន៍ភ្នំព្រិច ព្រៃសហគមន៍ភ្នំឆ្នោត ស្ថិតក្នុងខេត្តក្រចេះ ព្រៃសហគមន៍វាលអូរក្តី និងព្រៃសហគមន៍ក្បាលខ្លា ស្ថិតក្នុងខេត្តកំពង់ធំ)

- សហការជាមួយគម្រោងរ៉េដបូកកម្ពុជា-កូរ៉េ គាំទ្រលើការដើរល្បាតការពារព្រៃសហគមន៍ចំនួន ១៤កន្លែង នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- សិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ និងដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួន ១៤គ្រឿង ដើម្បីថតចាប់យករូបភាពសត្វព្រៃគ្រប់ប្រភេទ កត្តាគំរាមកំហែង និងរៀបចំពង្រាងរបាយការណ៍សិក្សាស្រាវជ្រាវក្នុងតំបន់គម្រោងរេដបូកទំរីង ខេត្តកំពង់ធំ

- ចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃស្ថិតនៅក្នុងសហគមន៍ព្រៃឈើប្រាសាទទឹកខ្មៅ ខេត្តក្រចេះ ដោយបានដំឡើងម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ៥គ្រឿង ដើម្បីពិនិត្យ តាមដាន និងផ្ទៀងផ្ទាត់ពីវត្តមាន និងប្រភេទសត្វព្រៃដែលកំពុងរស់នៅ និងបន្តពូជនៅក្នុងតំបន់

- ចុះសិក្សាស្រាវជ្រាវស្វែងរកសំបុកសត្វស្លាប ដោះអន្ទាក់ និងដំឡើងម៉ាស៊ីនថតស្វ័យប្រវត្តិស្ថិតក្នុងដែនជម្រកសត្វព្រៃកែវសីមា ខេត្តមណ្ឌលគិរី

- ចុះពង្រឹងការថែរក្សាសត្វព្រៃចំនួន ១លើកនៅសហគមន៍ព្រៃឈើប្រាំបីមុម ខេត្តកំពង់ស្ពឺ ដោយដោះ អន្ទាក់ខ្សែនីឡុងចំនួន ២៦ខ្សែ ចេញពីផ្លូវសត្វព្រៃឆ្លងកាត់

- ចុះសិក្សាកំណត់តំបន់សក្តានុពលទេសចរណ៍ធម្មជាតិចំនួន ១លើក នៅខេត្តមណ្ឌលគិរី

- ចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៤៣ច្បាប់ ក្នុងនោះ ៣០ច្បាប់សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង១៣ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេង មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កំពង់ធំ សៀមរាប បន្ទាយមានជ័យ ក្រចេះ ពោធិ៍សាត់ កណ្តាល កំពត និងខេត្តបាត់ដំបង

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន ៣០ច្បាប់ មានសត្វស្វាក្តាមសរុបចំនួន ១៣ ១៤៥ក្បាល សម្រាប់ដឹកជញ្ជូនទៅកាន់មាត់ច្រកអន្តរជាតិនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ៩ ៤៩៨ក្បាល និង៣ ៦៤៧ក្បាល ដឹកជញ្ជូនក្នុងស្រុក។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្តាមសរុបចំនួន១២៨ ៤៩៨ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៥៣ ៦៩៧ក្បាល

- កំពុងថែរក្សាសត្វព្រៃចំនួន ១ ៧៥៧ក្បាល (បក្សីចំនួន ៥៩ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ)

- សង្គ្រោះសត្វព្រៃថ្មីចំនួន ៤២៧ក្បាល ព្យាបាលចំនួន ២១៦ក្បាល និងស្តារលទ្ធភាពជីវសាស្ត្រ សត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ៧៧ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ២៦នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ២១ ០៣០ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ៣ហ.ត។

### ៣.៤ ការងារដាំដើមឈើ

- សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត និងមន្ទីរជំនាញពាក់ព័ន្ធអនុវត្តការងារចុះបញ្ជីដីទំហំ ៤៧,៦៧៧ហ.ត ដើម្បីបង្កើតសួនភូតគាម ស្ថិតក្នុងស្រុកបន្ទាយមាស ខេត្តកំពត

- ធ្វើសារពើភណ្ឌក្នុងចម្ការឈើដាំនៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើខ្នាររង្វាស់ ខេត្តសៀមរាប ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ៧៤៧ហ.ត ក្នុងនោះមានចម្ការពូជឈើទំហំ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ៣៩ហ.ត ចម្ការឈើដាំទំហំ៥៨៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា សរុបទំហំ៣០ហ.ត ស្ថិតក្នុងខេត្តកំពតកណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ឈូសឆាយសម្អាតដីសម្រាប់ដាំឈើជាចម្ការថ្មីទំហំ ១០៥ហ.ត (ខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំង) និងដាំឈើជាចម្ការបានទំហំ១០ហ.ត នៅខេត្តកំពង់ធំ

- រៀបចំទីតាំងប្រារព្ធពិធីរុក្ខទិវា ០៩កក្កដា ឆ្នាំ២០២២ ស្ថិតនៅភូមិសំបួរមាស ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង

- បណ្តុះកូនឈើគ្រប់ប្រភេទសរុបចំនួន ៣៨២ ០៧៣ដើម និងចែកចាយកូនឈើសម្រាប់ដាំអាស្រ័យផលបានចំនួន ៧៤ ៨៧០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ៣៥៤ករណី ក្នុងនោះ សំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ១១៧ករណី និងសំណុំរឿងបទល្មើសព្រៃឈើត្រូវបញ្ជូនទៅតុលាការចំនួន ២៣៧ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើបានចាប់ឃាត់ និងដកហូត រួមមាន ឈើមូល-ជ្រុងចំនួន ៧៧ម៣ ឈើអារសរុបចំនួន ៥៣៤ម៣ សត្វព្រៃចម្រុះប្រភេទចំនួន ៣ ៧៤៤ក្បាល ផ្ទៃដីព្រៃឈើកាប់រានទំហំ២ ៩៥៧ហ.ត

- វត្ថុតាងសត្វព្រៃ និងសំណាកសត្វព្រៃ បានប្រមូលតាមរយៈការប្រគល់-ទទួលមានចំនួន ១៨៦ករណី ធ្វើកិច្ចសន្យាចំនួន ៣៩ករណី និងធ្វើការដកហូតចំនួន ៥៣ករណី រួមមាន សត្វព្រៃរស់ចម្រុះប្រភេទចំនួន ៤៦៣ក្បាល សត្វព្រៃងាប់ចម្រុះប្រភេទចំនួន ៧ ២៤១ក្បាល និងសំណាកសត្វព្រៃចំនួន ១១៨,២០គ.ក្រ ទ្រូងអណ្តើកភ្នំចំនួន៣ ទ្រូងអណ្តើកសោមចំនួន១ ស្នួកអណ្តើកស្រែចំនួន១ និងក្រពះកាំប្រម៉ាចំនួន២

- ធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងដីព្រៃឈើតាមរយៈការបង់ប្រាក់ពិន័យដោយតុលាការចំនួន ៩ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ២កន្លែងស្ថិតក្នុងខេត្តកំពត និងខេត្តតាកែវ និងពន្យារសុពលភាពចំនួន ១០កន្លែងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកណ្តាល ស្វាយរៀង បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ ព្រៃវែង កំពង់ធំ និងខេត្តសៀមរាប

- ពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ៣កន្លែងនៅខេត្តស្ទឹងត្រែង និងខេត្តព្រះសីហនុ និងពន្យារសុពលភាពចំនួន ៧កន្លែងស្ថិតនៅរាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ កំពង់ធំ សៀមរាប ព្រះសីហនុ និងខេត្តព្រះវិហារ

- ក្រុមហ៊ុនចំនួន៨នាំចេញផលិតផលរានទេវតា និងឈើអារកែច្នៃទៅក្រៅប្រទេសមានបរិមាណចំនួន ៦៩៨ម៣ ជ័រទឹកចំនួន ៧៨តោន ធ្យូងអាកាស្យាចំនួន ៨១តោន និងចំណាំងកម្ទេចឈើចំនួន ៤ ៥០០តោន

- ក្រុមហ៊ុនចំនួន២នាំចូលឈើកែច្នៃមានបរិមាណចំនួន ១ ០១៦ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន៩មានឈើកែច្នៃចំនួន ៩៨៤ម៣ ចំណាំងកម្ទេចឈើចំនួន ៤ ៥០០តោន គ្រឿងសង្ហារឹមឬស្សីកែច្នៃចំនួន ៤២តោន ជ័រទឹកចំនួន ៥៦តោន និងធ្យូងអាកាស្យាចំនួន ៨៨តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន២មានឈើកែច្នៃចំនួន ៩៥២ម៣ ពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១មានឈើកែច្នៃចំនួន ២៨ម៣ និងពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន១មានឈើកែច្នៃចំនួន ១៥២ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួនសរុប ២ ៤៩៥ ១០៩ ៦០៨រៀល និង២៣៨ ០៤៦,៦៣ដុល្លារ។

## ៤ ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្មួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបចំនួន ១០៤ករណី ក្នុងនោះ ត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវ៧៦ករណី និងមិនមានលិខិតអនុញ្ញាតត្រឹមត្រូវ២៨ករណី (បទល្មើស)។ រាជធានី-ខេត្តចំនួន ២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៤០ ១៥៤លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**
  - ចុះប្រជុំផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៤
  - ចុះឃោសនាផ្សព្វផ្សាយជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៨
  - ចុះបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្តចំនួន២។
- **ការងារនីតិកម្ម និងវិវាទ**
  - កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ
  - កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្មលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១១៩ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ១៣ ៩១៥វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ ក្នុងឆមាសទី១ ឆ្នាំ២០២២នេះ វត្ថុវិភាគចំនួន ២១ដែលមានប្រភពមកពីភូមិលេខ៦ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ភូមិទ័ពស្តេច ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង និងបឹងស្នេហ៍ខេត្តព្រៃវែង វិជ្ជមាន H5N1 វត្ថុវិភាគចំនួន៤ដែលមានប្រភពមកពីភូមិត្រពាំងរុន ឃុំឫស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប វិជ្ជមាន H9N2 វត្ថុវិភាគចំនួន១១ដែលមានប្រភពមកពីសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ភូមិក្រដាស ឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម ភូមិត្រែង ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង ភូមិក្រពើគម ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម និងខេត្តតាកែវ វិជ្ជមានជំងឺដុំពកស្បែកគោក្របី (LSD)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

- ដាយត្រីសម្រេចបានត្រឹមខែមីនាចំនួន ៦៥០តោន ស្មើនឹង៦,៥០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៦៦០តោន
- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ៩៤ ៨០០តោន ស្មើនឹង៣១,៦០% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៣៧ ៤០០តោន
- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ២១ ១០០តោន ស្មើនឹង១៥,០៧% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៩០០តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៥៧ ៨០០តោន ស្មើនឹង៤៤,៤៦% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ កើនឡើងចំនួន ៤០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២៥ ០០០តោន ស្មើនឹង៦,៩៤% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ១១៩ ៣៤០តោន
- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៥៥ ៣០០ក្បាល ស្មើនឹង១៨,៤៣% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៣៦ ៩០០ក្បាល
- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៧៣ ៨០០ ០០០កូន ស្មើនឹង២៤,៦០% នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួនប្រមាណ ១០ ៥០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ២១ ៥០០តោន ស្មើនឹង២៦,៨៨% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៤ ៤១០តោន
- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៥ ៨៧០តោន ស្មើនឹង៤៨,៩២% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ២៦០តោន
- ការផលិតទឹកត្រីអនុវត្តបានចំនួន ៣១ ៧៥០ ០០០លីត្រ ស្មើនឹង៦៣,៥០% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៣ ០០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ៩៤៩ករណី ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ២៦២ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៨៥៩ករណី និងសមុទ្រចំនួន ៩០ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ១ ៤៤៩តោន ស្មើនឹង១៨,១១% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៤៩៦តោន
- ផលនេសាទកែច្នៃនាំចេញចំនួន ៤១តោន ស្មើនឹង២,០៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ១០៦តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ៤១៥ ៧០៣ ៥០៣រៀល ស្មើនឹង១១៥,៧៣% នៃផែនការចំនួន ៣៥៩ ២០០ ០០០រៀល ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៩ ២២២ ៦២៥រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចុះពិនិត្យតាមដាន និងវាយតម្លៃលើការងារបង្ក្រាបបទល្មើសជលផលនៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ កែប និងខេត្តកំពត
- ចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅខេត្តកំពង់ចាម
- ទទួលពាក្យបណ្តឹងចំនួន ២ករណី

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៤៨៤ករណី លើវិស័យព្រៃឈើ១៣៣ករណី ជលផល១៤៦ករណី សុខភាពសត្វនិងផលិតកម្មសត្វ៤៨ករណី កៅស៊ូ៧ករណី ក្សេត្រសាស្ត្រ៥ករណី នីតិកម្ម៥ករណី និងវិស័យផ្សេងៗ១៤០ករណី។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៤ ១៤០ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ១ ៦៧៦ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ១ ៨១៣ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៦៥១ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៦ ២៣៥ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៣៣០ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៤២ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំឆមាសទី១

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- រៀបចំកិច្ចប្រជុំផ្ទៃក្នុង (អន្តរនាយកដ្ឋាន) ចំនួន ៧លើក មានសមាជិកចូលរួមចំនួន ២៣៦នាក់ និងកិច្ចប្រជុំអន្តរក្រសួងចំនួន ២លើក មានសមាជិកចូលរួមចំនួន ៨៥នាក់

- ទទួលភ្ញៀវអន្តរជាតិចំនួន ៣លើក មានសមាជិកចូលរួមចំនួន ៤៥នាក់

- សិក្ខាសាលាចំនួន ៥លើក មានសមាជិកចូលរួមចំនួន ៨៩២នាក់

- សរុបការរៀបចំកិច្ចប្រជុំ និងការទទួលភ្ញៀវមានចំនួន ១៧លើក មានសមាជិកចូលរួមចំនួន ១ ២៥៨នាក់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញ ផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៩០៨នាក់ (ស្រី១ ៤៥៩នាក់ ស្មើនឹង២៤,៧០%) រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩៧២នាក់ (ស្រី៨៥១នាក់ ស្មើនឹង២៨,៦៣%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៣៦នាក់ (ស្រី៦០៨នាក់ ស្មើនឹង២០,៧០%)

- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៧២នាក់ (ស្រី១៤នាក់)

- រៀបចំប្រកាសស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ៥៩នាក់ (ស្រី១២នាក់) ផ្ទេរទៅក្រៅក្រសួងចំនួន ១៦នាក់ (ស្រី១នាក់)

- រៀបចំប្រកាសស្តីពីការទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការផ្ទេរមកពីក្រៅក្រសួង ចំនួន ១៨នាក់ (ស្រី៣នាក់)

- រៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌដោយមរណភាពចំនួន ២៣នាក់ (ស្រី៥នាក់) និងដោយលាឈប់ចំនួន ៣នាក់ (ស្រី១នាក់)

- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកសរុបចំនួន ៤៨នាក់ (ស្រី២៤នាក់)

- រៀបចំប្រកាសស្តីពីការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ២៣នាក់ (ស្រី៣នាក់)

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ១ ៣៥៦នាក់ (ស្រី៤០៧នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ១ ២៧៣នាក់ (ស្រី៣៩៣នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ៨៣នាក់ (ស្រី១៤នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- រៀបចំសំណើសុំផ្តល់យោបល់លើសេចក្តីព្រាងគោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧

- រៀបចំសំណើសុំផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបទដ្ឋានអនាម័យភូតគាមអនាម័យ និងដំណើរការរដ្ឋបាលសម្រាប់ការនាំចូលផ្លែស្រកានាគមកកម្ពុជា

- រៀបចំសំណើសុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០

- រៀបចំសំណើសុំការអនុញ្ញាតធ្វើការដោះដូរស្រូវពូជចំនួន ៤ ២៧៥តោន

- ពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៩-២០២៣ បន្ទាប់ពីបានចូលរួមកិច្ចប្រជុំអន្តរក្រសួងកម្រិតនយោបាយ និងបានបញ្ជូនរបាយការណ៍នេះ ជូនទៅក្រសួងផែនការ

- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០

- រៀបចំលិខិតផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥

- ចុះពិនិត្យ និងប្រមូលឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីដីឯកជនរបស់រដ្ឋក្នុងគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចតាមបណ្តាក្រុមហ៊ុនដើម្បីថែរក្សាទុកនៅខេត្តត្បូងឃ្មុំ ក្រចេះ មណ្ឌលគិរី កំពង់ធំ ព្រះសីហនុ និងខេត្តកំពត

- ចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការងារធ្វើអង្កេតស្ទង់ទិន្នផលស្រូវ

- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥

- ចុះពិនិត្យតាមដានការស្រង់ព័ត៌មានតម្លៃទីផ្សារកសិកម្មនៅខេត្តបាត់ដំបង ប៉ៃលិន ឧត្តរមានជ័យ និងខេត្តព្រះវិហារ

- ចុះតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពក្នុងក្របខ័ណ្ឌថវិកាកម្មវិធីចំនួន ១១ខេត្ត រួមមាន ខេត្តរតនគិរី កំពង់ចាម ព្រះវិហារ កំពង់ឆ្នាំង បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន តាកែវ កែប ស្វាយរៀង និងខេត្តកោះកុង។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ១៦ ៣០៧ លានរៀល ស្មើនឹង៤៤%ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២

- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ៥៥ ៣២២លានរៀល ស្មើនឹង៣៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២

- ទទួលបង្កាន់ដៃបង់ប្រាក់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ៤៧ក្រុមហ៊ុន

- រៀបចំឯកសារសម្រាប់ដំណើរការដេញថ្លៃសរុបចំនួន ១៧គម្រោង

- ចូលរួមតាមដានការប្រើប្រាស់ ការកត់ត្រាទិន្នន័យ និងគ្រប់គ្រងការបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ និងខេត្តកំពង់ចាម

- ចុះពិនិត្យ និងផ្ទៀងផ្ទាត់តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋសម្រាប់ឆ្នាំ២០២១ របស់រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ អគ្គនាយកដ្ឋានកៅស៊ូ រដ្ឋបាលជលផល អគ្គាធិការដ្ឋាន នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានកសិ-ឧស្សាហកម្ម នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋាននីតិកម្មកសិកម្ម វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម សាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ ខេត្តព្រះសីហនុ កំពង់ចាម កែប ត្បូងឃ្មុំ សៀមរាប ពោធិ៍សាត់ ព្រះវិហារ កំពត កំពង់ធំ កោះកុង និងខេត្តកណ្តាល

- ចូលរួមប្រជុំ ចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង បាត់ដំបង ប៉ៃលិន រតនគិរី មណ្ឌលគិរី ព្រៃវែង កំពង់ចាម និងខេត្តកំពង់ធំ ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះក្នុងឆ្នាំ២០២១ ធ្វើសំណើសុំជម្រះសម្ភារខូចខាតប្រើប្រាស់លែងកើត និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេស ថែទាំ និងជួសជុល

- រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស

- ចុះធ្វើសវនកម្មចំនួន ១៦សវនដ្ឋាន ស្មើនឹង៤១,១០% នៃផែនការ៣៩សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន៥០អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥៩,៨៤% នៃផែនការចំនួន៥៦%។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- សម្របសម្រួលរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-នូវែលសេឡង់ ដើម្បីត្រៀមរៀបចំកិច្ចពិគ្រោះយោបល់ក្រសួងការបរទេសកម្ពុជា-នូវែលសេឡង់ លើកទី២

- សម្របសម្រួលរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យវាយតម្លៃហានិភ័យផ្លែមៀនកម្ពុជាសម្រាប់នាំចេញទៅកាន់ប្រទេសចិន

- សម្របសម្រួលដើម្បីកំណត់យកតារាងនិយ័តកម្មថវិកានៃគម្រោងការកសាងសមត្ថភាពរបស់សមាជិកនៃប្រទេសតាមដងទន្លេមេគង្គ ដើម្បីការពារសត្វផ្សោតទឹកសាប និងជីវចម្រុះ

- សម្របសម្រួលដើម្បីបន្តសុពលភាពអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងកសិ-ពាណិជ្ជកម្មរវាងក្រសួងកសិកម្មហ្វីលីពីន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមការស្នើរបស់ភាគីហ្វីលីពីនតាមរយៈក្រសួងការបរទេស

- សម្របសម្រួលធ្វើលិខិតជូនក្រសួងការបរទេសសុំផ្តល់មតិយោបល់ ធាតុចូលលើសេចក្តីព្រាងឯកសារផែនការសកម្មភាពប្រាំឆ្នាំនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (២០២៣-២០២៧)

- បាននិងកំពុងសម្របសម្រួលធ្វើលិខិតរបស់អង្គការ Eclosio ដើម្បីបន្តចុះកិច្ចព្រមព្រៀងជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានទឹកប្រាក់ ២ ១៧៣ ១១៣ដុល្លារអាមេរិក

- រៀបចំលិខិតឆ្លើយតបទៅក្រសួងពាណិជ្ជកម្មលើករណីសំណើសុំពិនិត្យ និងផ្តល់យោបល់បន្ថែមលើការផ្តល់ព័ត៌មានអំពីវិធានការបានដាក់ចេញក្នុងអំឡុងពេលរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ ក្រោមសេចក្តីសម្រេចស្តីពីនីតិវិធីផ្តល់ព័ត៌មានសម្រាប់ការរឹតត្បិតបរិមាណទំនិញនាំចេញ-នាំចូលរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)

- សម្របសម្រួលកិច្ចការងារចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចំនួន ២គម្រោង គិតជាទឹកប្រាក់សរុបចំនួន ២ ៤១៤ ១១៣ដុល្លារអាមេរិក។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៥១ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៥២ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៣ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥៥ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ១២ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៥៧ក្រុមហ៊ុន សរុបចំនួន ៣៥៧សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្មនៅខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់

- សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈនៅខេត្តកំពង់ធំ ព្រះវិហារ កំពង់ចាម ត្បូងឃ្មុំ និងខេត្តកណ្តាល។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៩ក្រុមហ៊ុន។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ដកស្រង់ព័ត៌មានកសិកម្មប្រចាំថ្ងៃចេញពីបណ្តាញផ្សព្វផ្សាយសារព័ត៌មានសរុបចំនួន ៩៨៩ព័ត៌មាន
- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- ចុះតាមដាន និងពង្រឹងការប្រើប្រាស់គេហទំព័ររបស់មន្ទីរ និងប្រមូលធាតុចូលសម្រាប់បង្កើតកម្មវិធីទូរស័ព្ទនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន៨ រួមមាន ខេត្តកំពង់ស្ពឺ តាកែវ កោះកុង កែប កំពង់ចាម ស្វាយរៀង ព្រៃវែង និងខេត្តត្បូងឃ្មុំ
- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១
- ចុះប្រមូលទិន្នន័យដំណាំសក្តានុពលក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដើម្បីរៀបចំជាផែនទីដំណាំកសិកម្ម ស្ថិតនៅក្នុងភូមិសាស្ត្រចំនួន២ គឺឃុំត្រពាំងឫស្សី និងឃុំកំពង់ស្វាយ មានដំណាំសំខាន់ៗដូចជា ដំណាំស្រូវ ស្វាយ ស្វាយចន្ទី កៅស៊ូ អាកាស្យា ខ្នុរ អំពៅ ស្រកានាគ និងដំណាំព្រៃឈើ សម្រាប់ការគូស Digitizing Land Use ទៅលើមុខដំណាំសក្តានុពលនៅក្នុងស្រុកកំពង់ស្វាយបានចំនួន២៥%នៃមុខដំណាំកសិកម្ម
- ទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តីដែលទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ២៩០ក្បាល/ច្បាប់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះថតផលិត Video បទយកការណ៍ចំនួន ២ប្រធានបទ
- ចុះថត និងផលិត Video បទយកការណ៍ចំនួន ៥ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញវេទិកាស្វែងយល់អំពីកសិកម្មចំនួន ៨ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញនាទីចុះស្រែជាមួយកសិករចំនួន ៨ប្រធានបទ
- ធ្វើការចាក់ផ្សាយអត្ថបទបច្ចេកទេសកសិកម្មជាសំឡេងនៅស្ថានីយវិទ្យុជាតិ FM105.70.75MHZ ចំនួន ៣៦ប្រធានបទ
- ផ្សព្វផ្សាយពី Video បច្ចេកទេសកសិកម្មចំនួន ៦៦Video ឯកសារជាអត្ថបទបច្ចេកទេសកសិកម្មចំនួន ៧២ឯកសារ
- ជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនចំនួន ២២សំណួរ-ចម្លើយលើប្រធានបទបច្ចេកទេសចិញ្ចឹមមាន់ ទា គោ កង្កែប ដំឡូងមី ពោត ស្រូវ សណ្តែក ស្ពៃ ដំណាំម្ទេស និងដំណាំផ្សិត មកពីខេត្តពោធិ៍សាត់ ត្បូងឃ្មុំ កំពង់ស្ពឺ កំពង់ឆ្នាំង តាកែវ កណ្តាល កំពង់ចាម ស្វាយរៀង បន្ទាយមានជ័យ បាត់ដំបង ព្រៃវែង និងរាជធានីភ្នំពេញ។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ១៣២កិច្ចសន្យា គិតត្រឹមខែមេសា ឆ្នាំ២០២២ រួមមាន ខេត្តពោធិ៍សាត់ ៥កិច្ចសន្យា ស្ទឹងត្រែង៧កិច្ចសន្យា តាកែវ១កិច្ចសន្យា មណ្ឌលគិរី១កិច្ចសន្យា កំពង់ស្ពឺ២៨កិច្ចសន្យា កែប៤កិច្ចសន្យា កណ្តាល៥កិច្ចសន្យា ព្រះវិហារ១កិច្ចសន្យា ត្បូងឃ្មុំ១៩កិច្ចសន្យា សៀមរាប១១កិច្ចសន្យា កំពង់ចាម៤កិច្ចសន្យា ស្វាយរៀង ៣កិច្ចសន្យា បន្ទាយមានជ័យ១៥កិច្ចសន្យា ក្រចេះ១៤កិច្ចសន្យា កំពង់ធំ២កិច្ចសន្យា និងខេត្តកំពង់ឆ្នាំង១២កិច្ចសន្យា
- ចុះសម្របសម្រួលបណ្តុះបណ្តាលបុគ្គលិកអំពីប្រព័ន្ធសុវត្ថិភាពចំណីអាហារ (HACCP) និងចុះពិនិត្យការអនុវត្ត និងគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពក្នុងការកែច្នៃគ្រាប់ស្វាយចន្ទីនៅខេត្តកំពង់ធំ
- ចុះប្រមូលទិន្នន័យ និងធាតុចូលសម្រាប់ការរៀបចំគោលការណ៍ណែនាំពាក់ព័ន្ធនឹងអាហារូបត្ថម្ភនៅខេត្តរតនគិរី មណ្ឌលគិរី និងខេត្តក្រចេះ
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តសៀមរាប និងខេត្តតាកែវ
- ចុះបណ្តុះបណ្តាលស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តកំពត និងខេត្តកោះកុង
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសក្រោយប្រមូលផលនៃផលិតកម្មកសិកម្មនៅខេត្តបាត់ដំបង និងខេត្តព្រះវិហារ
- ចុះសិក្សាគុណភាពគ្រាប់ស្វាយចន្ទីស្រស់ ដើម្បីទទួលធាតុចូលក្នុងការរៀបចំសេចក្តីព្រាងស្តង់ដារគ្រាប់ស្វាយចន្ទីស្រស់នៅខេត្តកំពង់ធំ កំពង់ចាម ព្រះវិហារ រតនគិរី និងខេត្តក្រចេះ

- បញ្ចូលទិន្នន័យ និងវាយតម្លៃលើផលិតផលចំនួន ៥០០ប្រភេទ ដែលទទួលបានពីការស្ទង់មតិពី៥រាជធានី-ខេត្ត រួមមាន ខេត្តសៀមរាប ព្រៃវែង កំពត ស្ទឹងត្រែង និងរាជធានីភ្នំពេញ

- បាននិងកំពុងពិភាក្សាពិគ្រោះយោបល់ និងរៀបចំពិធីការជាមួយអ្នកជំនាញការបច្ចេកទេស MRLs ដើម្បីអនុវត្តន៍ការសិក្សាស្រាវជ្រាវការកាត់បន្ថយកម្រិតកាកសំណល់ថ្នាំកសិកម្មក្នុងការដាំដុះប្រភេទដំណាំប្រភេទជីនាងវងដោយប្រើប្រាស់ថ្នាំពុលកសិកម្ម ក្លរភីរីហ្វូស និងសាយភឺមេហ្រ៊ីន

- វិភាគរកសមាសធាតុគីមី Moisture, Total Nitrogen, Organic Carbone, និង Phosphorous នៅក្នុងសំណល់លាមកសត្វពពែសំណល់ស្មៅ និងផ្សិត

- វិភាគរកសមាសធាតុ កាកសសៃ សំណើម ផេះ ខ្លាញ់ អាស៊ូត កាបូនហ្ស៊ីត្រាដ ប្រូតេអ៊ីន និង សារធាតុរ៉ែផ្សេងៗទៀតដូចជា កាល់ស្យូម ដែក សូដ្យូម ប៉ូតាស្យូម ម៉ាញ៉េស្យូម ផូស្វ័រ និងAflatoxin នៅក្នុងអង្ករចំនួន ២ប្រភេទ

- ជ្រើសរើសសំណាកផលិតផលអង្ករចំនួន ៧ប្រភេទ ដើម្បីធ្វើតេស្តវិភាគសមាសធាតុគីមីតាមការកំណត់របស់គម្រោង AFCI ដែលមានប្រមាណពី១០ ទៅ១៣ប៉ារ៉ាម៉ែត្រ (សំណើម ផេះ ខ្លាញ់ អាស៊ូត កាបូនហ្ស៊ីត្រាដ ប្រូតេអ៊ីន ស្ករ សារធាតុរ៉ែផ្សេងៗទៀតដូចជា: កាល់ស្យូម ដែក សូដ្យូម ប៉ូតាស្យូម ម៉ាញ៉េស្យូម ផូស្វ័រនិងវីតាមីន។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ប្រមូលប្រភេទពូជដំណាំថ្មីៗបន្ថែមទៀតបានចំនួន ៦ប្រភេទ សរុបមានចំនួន ៨៤សំណាក ឪឡឹក២សំណាក ម្ទេស១៥សំណាក ត្រឡាច១សំណាក ល្ពៅ២២សំណាក ត្រសក់៣៥សំណាក និងត្រប់៩សំណាក និងបន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានចំនួន ៣៩ប្រភេទ រួមមាន ស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៨ប្រភេទ សរុបចំនួន ២ ៦០១បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៩ ៣៧៧បញ្ជីក/សំណាក

- ធ្វើពិសោធន៍ចំនួន ៣៣ប្រភេទ នៅ១៣៣កន្លែង ព្រមទាំងបានធ្វើការអង្កេតស្រាវជ្រាវចំនួន ៣លើក

- រៀបចំបើកវគ្គបណ្តុះបណ្តាលកសិករ ជួបប្រជុំជាមួយកសិករ និងធ្វើទិវាស្រែបង្ហាញចំនួន ៤១លើក មានកសិករចូលរួមសរុបចំនួន ១ ២៦៤នាក់ (ស្រី៥១៧នាក់ ស្មើនឹង ៤១%)

- ក្នុងឆមាសទី១ ឆ្នាំ២០២២នេះ មានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ២១០ ០៦០នាក់ ដោយគិតជាមធ្យមមានប្រមាណ ១ ១៦៧នាក់/ថ្ងៃ

- បើកវគ្គបណ្តុះបណ្តាលជំនាញនៅវិទ្យាស្ថានចំនួន ៤លើក មានសិក្ខាកាមចូលរួម ៩៦នាក់ (ស្រី២៦នាក់ ស្មើនឹង២៧%)

- ទទួលជួបបង្ហាញនូវលទ្ធផលការងារពិសោធន៍ស្រាវជ្រាវ និងពិភាក្សាជាមួយគណៈប្រតិភូ ភ្ញៀវជាតិ និងអន្តរជាតិចំនួន ៥លើក មានភ្ញៀវសរុប ១៩នាក់ (ស្រី៤នាក់ ស្មើនឹង២១%)។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២២សរុបចំនួន ៣ ១៤៤នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- ចុះអនុស្សរណៈយោគយល់លើកិច្ចសហការរវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- ពិភាក្សាជាមួយនាយកអង្គការ ILO ប្រចាំកម្ពុជារៀបចំកិច្ចព្រមព្រៀងផ្តល់នូវវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពឯកសារមេរៀន និងឧបករណ៍បង្រៀនជូនដល់មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងតាមសហគមន៍កសិកម្មនានាតាមបណ្តាខេត្ត

- ប្រជុំពិភាក្សាជាមួយសាកលវិទ្យាធិការនៃសាកលវិទ្យាល័យស្ត្រី Duk Sung នៃសាធារណរដ្ឋកូរ៉េ ក្នុងការរៀបចំបង្កើតវិទ្យាស្ថានភាសាកូរ៉េ ស្តេច សេជុង

- ប្រជុំពិភាក្សាជាមួយសាកលវិទ្យាល័យ Yunnan នៃសាធារណរដ្ឋប្រជាមានិតចិន ពិភាក្សាអំពីការសិក្សាស្រាវជ្រាវរួមគ្នាលើដំណាំផ្កា

- រៀបចំសិក្ខាសាលាស្តីពីការចម្រាញ់សារធាតុ សេរីស៊ីន ចេញពីសំបុកដង្កូវនាងសម្រាប់ធ្វើគ្រឿងសំអាង។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២២ សរុបចំនួន ១ ១២០នាក់ (ស្រី៤៦៤នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងសៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្តោតលើៈ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្តៅ អាហារ ថ្នាំសត្វល្អិត និងដី

- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតម្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២២ សរុបចំនួន ៥៩៤នាក់ (ស្រី២០៩នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- ពិសោធន៍លើការចម្រាញ់ប្រេងរុក្ខជាតិដូចជា ស្លឹកគ្រៃ ស្លឹកក្រូចសើច និងម្រេច
- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប
- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- តាមដាន ស្រង់ និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ក្នុង និងក្រៅស្ថានីយបានចំនួន ១២ចម្ការពិសោធន៍
- ត្រួតពិនិត្យការប្តូរមុខចៀរ និងផ្ទាំងចៀរចម្ការពិសោធន៍នៅក្នុងស្ថានីយចំនួន ១១ចម្ការ (IR.AA.01ដល់ IR.AA.10 និង IR.SSCT.01)
- បើកមុខចៀរចម្ការពិសោធន៍ក្លូនបានចំនួន ៤ចម្ការ (IR.AA.11, PV.AA.01, PV.AA.02 និង Test ចៀរជ័រ ចម្ការ IR.GSET.02)
- ស្រង់ទិន្នន័យជំងឺ Oidium នៃចម្ការពិសោធន៍ក្លូនសរុបបានចំនួន ១០ចម្ការ គឺIR.AA.01ដល់ IR.AA.10
- តាមដាន ស្រង់ បញ្ចូលទិន្នន័យគ្រប់ចម្ការពិសោធន៍នៅក្នុងស្ថានីយចំនួន១៣ និងក្រៅស្ថានីយចំនួន១ (ទំហំដើម ទិន្នផល និងជំងឺស្ងួតមុខចៀរ) (TPD)
- អនុវត្តការងារពិសោធន៍លើការលាបថ្នាំរំញោច
- រៀបចំបង្កើតចម្ការពិសោធន៍ថ្មីអំពីការគ្រប់គ្រងផ្ទាំងចៀរលើក្លូន IRCA 317 និង RRIC 100
- រៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីរទឹកជ័រ (Latex diagnosis-LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (R-SH)
- វិភាគរកស្តង់ដារសរីរសាស្ត្រទឹកជ័រ (LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (RSH) ដើម្បីផ្ទៀងផ្ទាត់សារធាតុគីមី
- សហការជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងអង្គការ WWF កម្ពុជា ត្រួតពិនិត្យ និងប្រមូលទិន្នន័យចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រនៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី
- អនុវត្តការបំប៉ៅកូនកៅស៊ូសម្រាប់ដាំដុះកៅស៊ូឆ្នាំ២០២២
- បាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្កាកុលាបលើកៅស៊ូផ្តល់ផលលើកទី១
- ដាំដុះកូនកៅស៊ូឆ្នាំ២០២២ ក្លូនRRIM600 ចំនួន៦,២៥ហ.ត

- រៀបចំបើកមុខចៀរដំរនៅចម្ការថ្មី និងក្រិតកំណត់សំបកចៀរសម្រាប់អនុវត្តការចៀរដំរនៅឆ្នាំ២០២២
- ត្រួតពិនិត្យការបែងចែកថ្នាំរំញោចសម្រាប់ប្រើប្រាស់នៅពេលចាប់ផ្តើមបើកមុខចៀរដំបូង
- ត្រួតពិនិត្យសម្ភារ និងឧបករណ៍មន្ទីរពិសោធន៍ជាតិយថាប្រភេទ
- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) សរុបចំនួន ៤២សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដា CSR។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបានចំនួន ១ ៤៨៣ ១៧២ហ.ត ស្មើនឹង៥៦,៦២% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្ម
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះដាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) និងជំងឺឆ្លងសត្វផ្សេងៗ

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្តត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កផ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

### ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

### ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជីកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់

ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្ដែង រួមទាំងការរៀបចំវគ្គបណ្ដុះបណ្ដាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្ដង់ដារ។

ថ្ងៃ សុក្រ ១០កើត ខែ បឋមាសាឍ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**